ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ០០១/២៦ ក.ប/ស.ជ.ល

# សេចក្តីជូនដំណឹង
# ស្តីពី
# ការប្រឡងតេស្តសមត្ថភាពភាសាកូរ៉េ ក្រោមប្រព័ន្ធអនុញ្ញាតមុខរបរលើកទី២៣ (23rd EPS-TOPIK) និងការប្រឡងតេស្តជំនាញ (Skill Test) សម្រាប់វិស័យកសិកម្ម

យោងលិខិត EPS-187 ចុះខែមករា ឆ្នាំ២០២៦ របស់អង្គភាពអភិវឌ្ឍន៍ធនធានមនុស្ស (HRD-Korea) នៃក្រសួងមុខរបរ និងការងារនៃសាធារណរដ្ឋកូរ៉េ គណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស(គ.ប.ប.ព.ប) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជូនដំណឹងដល់សាធារណជនដែលមានបំណងស្វែងរកការងារធ្វើនៅសាធារណរដ្ឋកូរ៉េ ឱ្យបានជ្រាបថា អង្គភាព HRD-Korea សហការជាមួយ គ.ប.ប.ព.ប នឹងរៀបចំការប្រឡងតេស្តសមត្ថភាពភាសាកូរ៉េ ក្រោមប្រព័ន្ធអនុញ្ញាតមុខរបរលើកទី២៣ (23rd EPS-TOPIK) និងការប្រឡងតេស្តជំនាញ (Skill Test) សម្រាប់វិស័យកសិកម្ម ដែលមានព័ត៌មានលម្អិតដូចខាងក្រោម៖

## ១. លក្ខខណ្ឌដើម្បីដាក់ពាក្យប្រឡង

- ត្រូវមានកាយសម្បទាគ្រប់គ្រាន់ និងសុខភាពល្អ (មិនពិការដៃ-ជើង និងងងឹតពណ៌ភ្នែក)
- ត្រូវមានអាយុចាប់ពី ១៨ ដល់ ៣៩ឆ្នាំ (កើតចន្លោះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៨៦ ដល់ថ្ងៃទី២១ ខែមករា ឆ្នាំ២០០៨)
- មិនមានប្រវត្តិប្រព្រឹត្តបទល្មើស មិនធ្លាប់ជាប់ពន្ធនាគារ ឬទោសឧក្រិដ្ឋ
- មិនមានការហាមឃាត់ក្នុងការចាកចេញពីព្រះរាជាណាចក្រកម្ពុជា
- មិនធ្លាប់ធ្វើការខុសច្បាប់នៅសាធារណរដ្ឋកូរ៉េ ឬបណ្តេញចេញពីសាធារណរដ្ឋកូរ៉េ
- មិនធ្លាប់ស្នាក់នៅ និងធ្វើការនៅសាធារណរដ្ឋកូរ៉េលើសពី ៥ឆ្នាំ (ប្រភេទទិដ្ឋាការ E-9 និងE-10) លើកលែងការបន្តដោយស្វ័យប្រវត្តិក្នុងអំឡុងពេលរីករាលដាលជំងឺកូវីដ-១៩។

## ២. ការចុះឈ្មោះសុំសិទ្ធិប្រឡង

- ចាប់ពីថ្ងៃពុធ ទី២១ ដល់ថ្ងៃសៅរ៍ ទី២៤ ខែមករា ឆ្នាំ២០២៦
- បេក្ខជនត្រូវចុះឈ្មោះតាមកម្មវិធី EPS-TOPIK Cambodia ដែលអាចទាញយកពី Play Store ឬ គេហទំព័រ www.eps.mtosb.gov.kh
- តម្លៃសុំសិទ្ធិប្រឡងបង់ជូនទៅអង្គភាពអភិវឌ្ឍន៍ធនធានមនុស្ស (HRD-Korea) នៃក្រសួងមុខរបរ និងការងារនៃសាធារណរដ្ឋកូរ៉េ៖ ២៨ដុល្លារ (ម្ភៃប្រាំបីដុល្លារសហរដ្ឋអាម៉េរិក)។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

❖ **ឯកសារចាំបាច់សម្រាប់ទាញចូលក្នុងកម្មវិធី**

- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ដែលមានសុពលភាពប្រើប្រាស់
- រូបថតពណ៌ធម្មជាតិដែលមិនមានការតុបតែង ទំហំ៣.៥ x ៤.៥ សង់ទីម៉ែត្រ (ផ្ទៃខាងក្រោយពណ៌ស ថតក្នុងអំឡុងពេល ៣ខែថ្មីៗនេះ)។

## ៣. កាលបរិច្ឆេទ និងមណ្ឌលប្រឡង

❖ **ការប្រឡងតេស្តសមត្ថភាពភាសាកូរ៉េ** (EPS-TOPIK)

- ការបិទឈ្មោះប្រឡង ៖ ថ្ងៃសុក្រ ទី១៣ ខែកុម្ភៈ ឆ្នាំ២០២៦ លើទំព័រហ្វេសប៊ុកផេកផ្លូវការរបស់ គ.ប.ប.ព.ប www.facebook.com/mtosbcambodia និងតេលេក្រាម https://t.me/epscambodia
- មណ្ឌលប្រឡង ៖ ជាន់ទី៤ អគារមជ្ឈមណ្ឌលសហប្រតិបត្តិការស្រាវជ្រាវ និងអភិវឌ្ឍន៍វិទ្យាសាស្ត្រ នៅក្នុងវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា (NPIC)
- កាលបរិច្ឆេទប្រឡង ៖ ចាប់ពីថ្ងៃចន្ទ ទី២៣ ខែកុម្ភៈ ឆ្នាំ២០២៦ តទៅ ដោយក្នុងមួយថ្ងៃមានការប្រឡងចំនួន ៤វេន៖

| វេនប្រឡង | ការពន្យល់ណែនាំពីរបៀបប្រឡង | រយៈពេលនៃការប្រឡង | |
|---|---|---|---|
| | | វិញ្ញាសាអាន(២៥នាទី) | វិញ្ញាសាស្តាប់(២៥នាទី) |
| វេនទី១ | ០៨:៣០~០៩:៣០ | ០៩:៣០~០៩:៥៥ | ០៩:៥៥~១០:២០ |
| វេនទី២ | ១០:០០~១១:០០ | ១១:០០~១១:២៥ | ១១:២៥~១១:៥០ |
| វេនទី៣ | ១២:៣០~១៣:៣០ | ១៣:៣០~១៣:៥៥ | ១៣:៥៥~១៤:២០ |
| វេនទី៤ | ១៤:០០~១៥:០០ | ១៥:០០~១៥:២៥ | ១៥:២៥~១៥:៥០ |

- បេក្ខជនត្រូវចូលក្នុងបន្ទប់រង់ចាំឱ្យបានមុនម៉ោងប្រឡង ដើម្បីស្តាប់ការពន្យល់ណែនាំពីរបៀបប្រឡង។ កាលវិភាគប្រឡងអាចមានការប្រែប្រួលស្របតាមការចាំបាច់របស់អង្គភាព HRD-Korea។

❖ **ការប្រឡងតេស្តជំនាញ** (Skill Test)

- ការបិទឈ្មោះប្រឡង ៖ ថ្ងៃព្រហស្បតិ៍ ទី៩ ខែមេសា ឆ្នាំ២០២៦ លើទំព័រហ្វេសប៊ុកផេកផ្លូវការរបស់ គ.ប.ប.ព.ប www.facebook.com/mtosbcambodia និងតេលេក្រាម https://t.me/epscambodia
- មណ្ឌលប្រឡង ៖ វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា (NPIC)
- កាលបរិច្ឆេទប្រឡង ៖ ចាប់ពីថ្ងៃអង្គារ ទី២១ ខែមេសា ឆ្នាំ២០២៦ តទៅ ដោយក្នុងមួយថ្ងៃមានការប្រឡងចំនួន ២វេន។

## ៤. ចំនួនបេក្ខជនប្រឡងជាប់ជាស្ថាពរ

- បេក្ខជនដែលប្រឡងជាប់ជាស្ថាពរចំនួន ៤,០០០នាក់។ ការកំណត់ពិន្ទុ គឺធ្វើឡើងដោយអង្គភាព HRD-Korea តាមលំដាប់ពិន្ទុពីខ្ពស់មកទាប
- ដើម្បីក្លាយជាបេក្ខជនប្រឡងជាប់ជាស្ថាពរ បេក្ខជនត្រូវឆ្លងកាត់ការប្រឡងតេស្តជំនាញ (Skill Test) ក្រោយពេលប្រកាសលទ្ធផលប្រឡងជាប់តេស្តសមត្ថភាពភាសាកូរ៉េ (EPS-TOPIK)។

## ៥. វិញ្ញាសាប្រឡង

❖ **វិញ្ញាសាប្រឡងតេស្តសមត្ថភាពភាសាកូរ៉េ** (EPS-TOPIK)

- វិញ្ញាសាអានមាន ២០សំណួរ (រយៈពេល ២៥នាទី) និងវិញ្ញាសាស្តាប់មាន ២០សំណួរ (រយៈពេល ២៥នាទី) វិញ្ញាសាទាំងពីរនឹងអនុវត្តបន្តបន្ទាប់គ្នាដោយពុំមានការឈប់សម្រាកឡើយ
- តេស្តងឹតពណ៌ភ្នែក។

❖ **វិញ្ញាសាប្រឡងតេស្តជំនាញ** (Skill Test)

- ជំនាញមូលដ្ឋាន កាយសម្បទា និងការសម្ភាសន៍។

❖ **ឯកសារដែលត្រូវយកមកជាមួយនៅថ្ងៃប្រឡង**

- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ច្បាប់ដើម (ដូចគ្នាទៅនឹងពេលដាក់ពាក្យសុំសិទ្ធិប្រឡង) ក្នុងករណីមិនបានយកមកជាមួយ នោះអង្គភាព HRD-Korea នឹងមិនអនុញ្ញាតឱ្យប្រឡងជាដាច់ខាត។

## ៦. ការប្រកាសលទ្ធផល

❖ **លទ្ធផលប្រឡងជាប់តេស្តសមត្ថភាពភាសាកូរ៉េ** (EPS-TOPIK)

- ថ្ងៃពុធ ទី៨ ខែមេសា ឆ្នាំ២០២៦
- ក្រោយពីប្រកាសលទ្ធផលជាប់តេស្តសមត្ថភាពភាសាកូរ៉េ (EPS-TOPIK) បេក្ខជនដែលមានវិញ្ញាបនបត្រជំនាញត្រូវនឹងវិស័យកសិកម្មអាចយកមកដាក់នៅអគារលេខ៨ នៃ គ.ប.ប.ព.ប ចាប់ពីថ្ងៃព្រហស្បតិ៍ ទី៩ ដល់ថ្ងៃសុក្រ ទី១០ ខែមេសា ឆ្នាំ២០២៦ ដើម្បីទទួលបានពិន្ទុបន្ថែមនៅពេលប្រឡងតេស្តជំនាញ។

❖ **លទ្ធផលប្រឡងជាប់ជាស្ថាពរ**

- ថ្ងៃព្រហស្បតិ៍ ទី៣០ ខែមេសា ឆ្នាំ២០២៦
- សុពលភាពនៃលទ្ធផលប្រឡងមានរយៈពេលចំនួន ២ឆ្នាំ គិតចាប់ពីថ្ងៃប្រកាសលទ្ធផល។

## ៧. ព័ត៌មានផ្សេងៗ

- មិនអនុញ្ញាតឱ្យយកចូលក្នុងបន្ទប់ប្រឡងនូវទូរសព្ទដៃ សំណៅឯកសារ វចនានុក្រមអេឡិចត្រូនិច និងឧបករណ៍អេឡិចត្រូនិចផ្សេងៗទៀតដែលអាចប្រើប្រាស់ក្នុងការលួចបន្លំ។ ក្នុងករណីដែលរកឃើញថាមានការលួចបន្លំ នោះការប្រឡងតេស្តនឹងចាត់ទុកជាមោឃៈ និងត្រូវដកសិទ្ធិប្រឡងក្នុងរយៈពេល ៤ឆ្នាំ
- ប្រសិនបើព័ត៌មានផ្ទាល់ខ្លួន (ឈ្មោះ ថ្ងៃខែឆ្នាំកំណើត និងភេទ) នៅលើអត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន មិនដូចគ្នានឹងព័ត៌មាននៅលើពាក្យសុំសិទ្ធិប្រឡងទេ នោះបេក្ខជននឹងមិនត្រូវបានចុះឈ្មោះទៅក្នុងបញ្ជីឈ្មោះអ្នកស្វែងរកការងារធ្វើក្រោមប្រព័ន្ធអនុញ្ញាតមុខរបរ EPS ក៏ដូចជាការបញ្ជូនទៅសាធារណរដ្ឋកូរ៉េឡើយ បេក្ខជនត្រូវទទួលខុសត្រូវទាំងស្រុងចំពោះបញ្ហាដែលបណ្តាលមកពីភាពខុសគ្នានៃព័ត៌មានទាំងនោះ។

- **បេក្ខជនជាប់ជាស្ពាត** មិនមានន័យថាបានប្រឡងជាប់ទៅធ្វើការនៅសាធារណរដ្ឋកូរ៉េឡើយ។
- បេក្ខជនដែលធ្លាក់តេស្តសុខភាព ឬធ្លាប់ស្នាក់នៅដោយខុសច្បាប់នៅសាធារណរដ្ឋកូរ៉េ មិនត្រូវបានអនុញ្ញាតឱ្យដាក់ពាក្យសុំស្វែងរកការងារធ្វើនៅសាធារណរដ្ឋកូរ៉េឡើយ បើទោះបីជាបានប្រឡងជាប់ជាស្ពាតក៏ដោយ។
- យោងអនុស្សរណៈយោគយល់ស្តីពីការបញ្ជូនពលករក្រោមប្រព័ន្ធអនុញ្ញាតមុខរបរ EPS មានតែគណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេសតែមួយប៉ុណ្ណោះ ដែលមានសិទ្ធិបញ្ជូនពលករកម្ពុជាទៅធ្វើការងារនៅសាធារណរដ្ឋកូរ៉េ។ មានតែបេក្ខជនដែលបានប្រឡងជាប់ជាស្ពាត និងបានចុះឈ្មោះចូលក្នុងបញ្ជីស្វែងរកការងារធ្វើប៉ុណ្ណោះ ដែលអាចត្រូវបានជ្រើសរើសដោយនិយោជកកូរ៉េតាមរយៈប្រព័ន្ធកុំព្យូទ័រ។ ភ្នាក់ងារឯកជនណាមួយដែលជាប់ពាក់ព័ន្ធនៅក្នុងដំណើរការបញ្ជូនពលករនឹងត្រូវធ្វើការផាកពិន័យតាមច្បាប់ជាធរមាន។
- ការប្រឡងតេស្តសមត្ថភាពភាសាកូរ៉េនេះរៀបចំដោយ ក្រសួងមុខរបរ និងការងារនៃសាធារណរដ្ឋកូរ៉េ និងអនុវត្តដោយអង្គភាពអភិវឌ្ឍន៍ធនធានមនុស្សនៃសាធារណរដ្ឋកូរ៉េ ដោយមានការសហការជាមួយគណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៃព្រះរាជាណាចក្រកម្ពុជា។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកគណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស ដែលមានទីតាំងអគារលេខ៨ ក្នុងវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា (NPIC) ភូមិព្រៃពពេល សង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឬតាមទូរសព្ទលេខ ០១២-៤៦៦-២២២ និង ០១២-២៥៣-៥៥៥ នៅរៀងរាល់ម៉ោងធ្វើការ។

ថ្ងៃ ព្រ ១១រោច ខែ បុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០២៦

**រដ្ឋមន្ត្រី**

**ហេង សួរ**

**<u>ចម្លងជូន</u>**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-ក្រសួងមហាផ្ទៃ

-ក្រសួង ស្ថាប័នពាក់ព័ន្ធ "ដើម្បីជ្រាប"

-រដ្ឋបាលរាជធានី ខេត្ត "ដើម្បីជ្រាប និងសហការ"

-មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត "ដើម្បីជួយផ្សព្វផ្សាយ និងសហការ"

-ឯកសារ កាលប្បវត្តិ